ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០០២......សហវ.[illegible]

# សេចក្តីណែនាំ
## ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំ ដូចតទៅ÷

### ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវអនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ តរៀងទៅ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែនីមួយៗ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម ÷

| គោលបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0៛ | ដល់ | ១ ២០០ ០០០៛ | 0% |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

### ២. ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភ័ស្តុតាងនៃស្ថានភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗ ១៥០ ០០០ រៀល ក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១ ២០០ ០០១ រៀល ដល់ ១ ៦០០ ០០០រៀល (ប្រមាណពី៣០០ ទៅ ៤០០ ដុល្លារអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## ៣. ការគណនាពន្ធលើប្រាក់បៀវត្ស

យោងតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស ដោយយកចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ ដោយឡែក ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធ ត្រូវបានអនុញ្ញាតឱ្យដកចេញបន្ថែមទៀតនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០១១ សហវ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ២០០ ០០០ រៀល ដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រា | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០៛ | ០ % | ០ ៛ |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥ % | ៦០ ០០០ ៛ |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០ % | ១៦០ ០០០ ៛ |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥ % | ៥៨៥ ០០០ ៛ |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០ % | ១ ២១០ ០០០ ៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស(ពបវ) = មូលដ្ឋានគិត ពបវ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ(លបព)

**កំណត់សម្គាល់÷**

ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ (បវ)។

**ឧទាហរណ៍ទី១** ÷ កម្មករនិយោជិត រោងចក្រ សហគ្រាស ម្នាក់មានប្រាក់បៀវត្ស ១ ៨០០ ០០០ រៀល ដែលក្នុងនោះមានប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរនិងថ្លៃបាយសរុបចំនួន ១០០ ០០០ រៀល។

**ក. ករណីនៅលីវ**

មពបវ = ១ ៨០០ ០០០៛ - ១០០ ០០០៛ = ១ ៧០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ៥%)

លបព = ៦០ ០០០៛

ពបវ = (១ ៧០០ ០០០៛ x ៥%) - ៦០ ០០០៛ = <u>**២៥ ០០០៛**</u>

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ១ ៨០០ ០០០៛ - ១០០ ០០០៛- ៦០០ ០០០៛= ១ ១០០ ០០០៛(ត្រូវជាប់ពន្ធតាមអត្រា ០%)

លបព = ០៛

ពបវ = (១ ១០០ ០០០៛ x ០%) - ០៛ = <u>**០៛**</u>

**ឧទាហរណ៍ទី២** ÷ អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់មានប្រាក់បៀវត្ស ៨ ៦០០ ០០០ រៀល

**ក. ករណីនៅលីវ**

មពបវ = ៨ ៦០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១៥%)

លបព = ៥៨៥ ០០០៛

ពបវ = (៨ ៦០០ ០០០៛ x ១៥%) - ៥៨៥ ០០០៛ = <u>**៧០៥ ០០០៛**</u>

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ៨ ៦០០ ០០០៛ - ៦០០ ០០០៛ = ៨ ០០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១០%)

លបព = ១៦០ ០០០៛

ពបវ = (៨ ០០០ ០០០៛ x ១០%) - ១៦០ ០០០៛ = <u>**៦៤០ ០០០៛**</u>

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ... ខែ ... ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី** សាស្ត្រាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ